# មេរៀនទី ១៣៤៖ ស្តេចអាប់សាឡំុមប៉ុនប៉ងដណ្តើមរាជ្យ

## ២ សាំយូអែល ១៥៖ ១-១២, ១៧៖ ១-១២, ១៨៖ ១-១៨

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/p9_wVpVXGIA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/W-7pEF-n1qA

**គោលបំណង៖ យើងលើកដំកើងព្រះដោយការទុកទ្រង់ជាទី១។**

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៦៖៣៣** *“ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង។”*

**ចំរៀង** ( *យូធូបលីង* )៖
១. ស្តេចលើស្តេច https://youtu.be/CPBqHYVwm3M
២. ចូរប្រយ័ត្ននឹងភ្នែកតូចអ្នក https://youtu.be/leoAGL9usF0
៣. ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ដណ្តើមស្លឹកឈើ»

សម្ភារៈដែលត្រូវការ៖ មែកឈើ១មែក



១. ចែកកុមារជា ២ក្រុម
២. ដាក់មែកឈើនៅចំកណ្តាល ដោយឲ្យកុមារឈរទល់មុខគ្នា
៣. គ្រូត្រូវដាក់លេខរៀងឲ្យគូរនីមួយៗ
៤. នៅពេលដែលគ្រូហៅលេខ កុមារដែលលឺលេខរៀងរបស់ខ្លួន ពួកគេត្រូវរត់ឲ្យលឿនមកកន្លែងដាក់មែកឈើ។ ពួកគេត្រូវដណ្តើមមែកឈើនោះទៅកាន់កន្លែងដើមវិញ ដោយមិនត្រូវឲ្យកុមារដែលមកពីក្រុមម្ខាងទៀតប៉ះគេបាននោះទេ។
៥. ឧទាហរណ៍៖ ប្រសិនបើគ្រូហៅ “គូរទី៣!” នោះអ្នកដែលមានលេខរៀងទី៣ ត្រូវរត់មកដណ្តើមមែកឈើនោះ ហើយរត់ត្រឡប់ទៅកាន់ក្រុមគេវិញឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។
៦. ប្រសិនបើក្រុមម្ខាងទៀតប៉ះគេបាននោះគេនឹងចាញ់ល្បែងនេះ។
៧. បន្តលេងល្បែងនេះ រហូតដល់កុមារទាំងអស់បានលេងគ្រប់គូរ។
៨. ក្រុមណាដែលទទួលបានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។
៩. តាមរយៈកាដណ្តើមស្លឹកឈើនេះអ្នកគ្រូនិងបង្ហាញប្អូននៅក្នុងសាចរឿង នៅថ្ងៃនេះអ្នកគ្រូនិងទិទានរឿងមួយក្នុងព្រះគម្ពីរអំពីកូនណ្តើមរាជ្យពីឪពុក ។

### ៤. ការណែនាំមេរៀន

ពេលដែលអ្នកភ្ញាក់ពីគេងពេលព្រឹក តើអ្នកគិតអីមុនគេ? តើអ្នកគិតថាត្រូវញ៉ាំអីពេលព្រឹក? គិតរឿងទៅសាលារៀន? ថ្ងៃនេះយើងនឹងរៀនពីការលើកដំកើងព្រះដោយទុកទ្រង់ជាទី១។ ពេលដែលយើងគោរព

នរណាម្នាក់ យើងបង្ហាញកាយវិការ ឬប្រើពាក្យសំដីដែលបង្ហាញថាបុគ្គលម្នាក់នោះអស្ចារ្យប៉ុណ្ណា។ ឧទាហរណ៍ដូចជា នៅពេលដែលអ្នកគោរពឪពុកម្តាយអ្នក អ្នកបង្ហាញ និងនិយាយថា ពួកគេសំខាន់ប៉ុណ្ណា ពីព្រោះពួកគេជាឪពុកម្តាយរបស់អ្នក ហើយពួកគេយកចិត្តទុកដាក់អ្នក។ វិធីមួយដែលយើងនាំការគោរព លើកដំកើងព្រះគឺដោយការទុកព្រះជាទី១នៅក្នុងជីវិតយើង ដោយការទៅព្រះវិហារសរសើរដំកើងព្រះជំនួសឲ្យការទៅធ្វើអ្វីផ្សេង ឧទាហរណ៍ ដូចជាអ្នកកំពុងនៅទីនេះដើម្បីគោរពលើកដំកើងព្រះដោយអ្នកទុកព្រះជាទី១។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ដាវីឌគឺជាស្តេចសាសន៍អ៊ីស្រាអែល ហើយគាត់គឺជាស្តេចដ៏ល្អ។ ដាវីឌស្រឡាញ់ព្រះ និងស្តាប់បង្គាប់ព្រះ។ ប៉ុន្តែនៅពេលដាវីឌនៅធ្វើជាស្តេច កូនប្រុសម្នាក់របស់ដាវីឌបានសំរេចចិត្តចង់ក្លាយទៅជាស្តេចជំនួសគាត់។ កូនគាត់ម្នាក់នោះមានឈ្មោះថា អាប់សាឡុំម។ អាប់សាឡុំមបានសំរេចចិត្តចង់ឲ្យប្រជាជនដើរតាមគាត់ជំនួសស្តេចដាវីឌ។ អាប់សាឡុំមបានធ្វើពុតជារួសរាយរាក់ទាក់ជាមួយនឹងប្រជាជនទាំងអស់នោះ តែអ្វីដែលគាត់ចង់បានពិតប្រាកដនោះ គឺចង់ឲ្យប្រជាជនទាំងអស់គ្នាជួយគាត់ឲ្យក្លាយទៅជាស្តេច។

អាប់សាឡុំមទទួលបានអ្នកដើរតាមដាវីឌមួយចំនួនមកដើរតាមគាត់ជំនួសវិញ។ ហើយមានប្រជាជនជាច្រើននៅខាងអាប់សាឡុំម។ ថ្ងៃមួយអាប់សាឡុំម និងអ្នកដើរតាមគាត់បានវាយប្រហារស្តេចដាវីឌ និងអ្នកដើរតាមស្តេចដាវីឌ។ អាប់សាឡុំមច្បាស់ណាស់ថាគាត់នឹងឈ្នះ ហើយនឹងក្លាយជាស្តេចបន្ទាប់របស់សាសន៍អ៊ីស្រាអែល។ ប៉ុន្តែព្រះមិនចង់ឲ្យរាស្ត្ររបស់ទ្រង់មានភាពអាត្មានិយម។ ព្រះចង់ឲ្យរាស្ត្ររបស់ទ្រង់តែងតែ ទុកព្រះអង្គជាទី១។ អាប់សាឡុំមមិនបានយកព្រះជាទី១ទេ គាត់ជាមនុស្សអាត្មានិយមខ្លាំងណាស់។

ស្តេចដាវីឌទុកព្រះជាទី១ និងលើកដំកើងព្រះ ហើយគាត់បានឈ្នះការប្រយុទ្ធ។ គាត់នៅតែជាស្តេច ហើយអាប់សាឡុំមមិនបានក្លាយទៅជាស្តេចទេ។

យើងលើកដំកើងព្រះដោយទុកព្រះជាទី១ មានន័យថាត្រូវរស់នៅតាមផ្លូវដែលព្រះចង់ឲ្យយើងរស់នៅ។ ព្រះចង់ឲ្យយើងសរសើរដំកើងព្រះអង្គ។ តើយើងអាចលើកដំកើងព្រះដោយទុកព្រះជាទី១បានដែរឬទេ?

## ៦. សំនួរពិភាក្សា

១. តើនរណាជាស្តេចរបស់អ៊ីស្រាអែល? *(ស្តេចដាវីឌ)*

២. តើអ្នកណាចង់ក្លាយជាស្តេចរបស់អ៊ីស្រាអែល? *(អាប់សាឡុំម ជាកូនប្រុសរបស់ស្តេចដាវីឌ)*

៣. ហេតុអ្វីបានជាព្រះជួយស្តេចដាវីឌឲ្យឈ្នះអាប់សាឡុំម?
*(ដោយសារស្តេចដាវីឌបានលើកតម្កើងព្រះដោយទុកព្រះជាទី១)*

៤. តើអ្នកអាចធ្វើអ្វីខ្លះដើម្បីលើកតម្កើងព្រះដោយទុកព្រះជាទី១? *(ស្រឡាញ់ព្រះ សប្បុរសចំពោះអ្នកដទៃ ស្តាប់បង្គាប់ឪពុកម្តាយយើង សរសើរដំកើងព្រះ និងធ្វើទង្វើល្អៗជាច្រើនទៀត)*

## ៧. ល្បែងកំសាន្ត «លួចសោលោកយាយ»



សម្ភារៈដែលត្រូវការៈ កូនសោរ១ចង្កោម ម៉ាសរឹកន្សែង

១. រកអ្នកចាំទីម្នាក់អង្គុយតំណាងជា "លោកយាយ"

២. ចែកកុមារជា២ក្រុមស្មើគ្នាអង្គុយជាជួរ

៣. ឲ្យ"លោកយាយ" អង្គុយនៅចំកណ្តាលរវាងក្រុមទាំងពីរ។ បិត ភ្នែក"លោកយាយ" ។
៤. ដាក់ចង្កោមសោរនៅ ពីមុខ"លោកយាយ"
៥. ក្រុមនីមួយៗត្រូវឲ្យកុមារម្នាក់មកទាញយកសោដែលនៅពីមុខ "លោកយាយ" ដោយស្ងៀមស្ងាត់។
៦. បន្ទាប់ពីសោរត្រូវបានលួចរួចនោះ "លោកយាយ" ត្រូវទាយថា តើសោរនោះនៅក្រុមខាងឆ្វេងឬខាងស្តាំ។ ប្រសិនបើ"លោកយាយ" ទាយខុស នោះក្រុមដែលបានលួចសោរនោះនឹងទទួលបានមួយពិន្ទុ។ ប៉ុន្តែ បើ"លោកយាយ" ទាយត្រូវនោះ ពួកគេមិនទទួលបានពិន្ទុនោះទេ។
៧. ក្រុមណាដែលទទួលបានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។
៨. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា នៅពេលដែលយើងលួចអ្វីមួយនោះ យើងបានបង្ហាញថា យើងមិនបានគោរពចាស់ទុំទេ ហើយយើងក៏មិនបានទុកព្រះជាទីមួយដែរ។ ព្រះនឹងសប្បាយព្រះទ័យនៅពេលដែលយើងទុកទ្រង់ជាទី១ ដោយការបង្ហាញសេចក្តីស្រលាញ់របស់យើងចំពោះអ្នកដទៃ។

## ៨. ខគម្ពីរចងចាំ

**ម៉ាថាយ ៦៖៣៣** *"ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំង នោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង។"*

## ៩. ហត្ថកម្ម

សូមផាត់ពណ៌រូបភាព "ដាវីឌទុកព្រះជាទី១"។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ជីវិតដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនរបស់ព្រះយេស៊ូវបានធ្វើឲ្យពិភពលោកមានភាពខុសគ្នាសម្រាប់យើង។ តើអាកប្បកិរិយាគិតតែពីខ្លួនឯងប៉ះពាល់ដល់ទំនាក់ទំនងយ៉ាងដូចម្តេច? តើការធ្វើតាម គំរូព្រះយេស៊ូវ ដែលមិនគិតប្រយោជន៍ផ្ទាល់ខ្លួនអាចពង្រឹងពួកគេយ៉ាងដូចម្តេច? តើយើងអាចរក្សាអាកប្បកិរិយា ព្រះ គ្រីស្ទជាកណ្តាលបានដោយរបៀបណា? ដោយសម្លឹងមើលទៅព្រះ គ្រីស្ទគ្រប់ពេលវេលា។ អរគុណព្រះ សម្រាប់ការបញ្ជូនព្រះយេស៊ូវ ដែលនាំយើងទៅកាន់ទំ នាក់ទំនងកាន់តែប្រសើរឡើង ដោយបង្ហាញយើង ពីរបៀបប្រព្រឹត្តចំពោះអ្នកដទៃ ដោយសេចក្តី ស្រឡាញ់ដែលមិនគិតតែពីខ្លួនឯង ពោលគឺរបៀបដែល ទ្រង់ប្រព្រឹត្តចំពោះយើង។

# ផាត់ពណ៌រូប ស្ដេចដាវីឌទុកព្រះជាទី១



សូមសរសេរខគម្ពីរចងចាំ: